វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- កម្ពុជា និងសាធារណរដ្ឋកូរ៉េពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច
- ទីក្រុងបាងកកជាប់ចំណាត់ថ្នាក់ ក្នុងចំណោមទីក្រុងដែលមានតម្លៃថ្លៃបំផុតទាំង១០ នៅតំបន់អាស៊ី
- ធនាគារសហព័ន្ធ រក្សាអត្រាថេរ ជាសញ្ញាបង្ហាញថាគ្មានការបង្កើនអត្រាការប្រាក់បន្ថែមសម្រាប់ឆ្នាំនេះ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជា និងសាធារណរដ្ឋកូរ៉េពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ឯកឧត្តម Moon Jae-in បានអញ្ជើញធ្វើទស្សនកិច្ចនៅរាជធានីភ្នំពេញ សម្រាប់កិច្ចប្រជុំទ្វេភាគីជាមួយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ពីថ្ងៃទី១៤ ដល់ ១៦ ខែមីនា កន្លងទៅនេះ។ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានធ្វើការពិភាក្សាប្រកបដោយភាពស្និទ្ធស្នាល និងបានឈានទៅដល់កិច្ចព្រមព្រៀងលើវិស័យមួយចំនួនដើម្បីជំរុញពាណិជ្ជកម្មទ្វេភាគី តាមរយៈការពង្រីកការចូលក្នុងទីផ្សារសម្រាប់ផលិតផលកម្ពុជា ជាពិសេសគឺផលិតផលកសិកម្ម និងការរួមគ្នាជំរុញបន្ថែមនូវភាពជាដៃគូយុទ្ធសាស្ត្រ អាស៊ាន-សាធារណរដ្ឋកូរ៉េ។

លទ្ធផលពិស្តារនៃកិច្ចប្រជុំ មាននៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល (pdf)។ ឯកសារកិច្ចសហប្រតិបត្តិការទាំង៧ ខាងក្រោមនេះ ត្រូវបានសម្រេចក្នុងអំឡុងពេលនៃទស្សនកិច្ច ៖

1. ការរៀបចំក្របខណ្ឌ ស្តីពីឥណទានសម្បទាន នៃមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣
2. កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់ការបង្កើតមន្ទីរពេទ្យសកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល
3. អនុស្សារណៈយោគយល់ ស្តីពីគម្រោង "ការផ្គត់ផ្គង់ថាមពលសម្រាប់ប្រព័ន្ធបណ្តាញអគ្គិសនីខ្នាតតូចបំផុត (Micro-grids) និងស្ថានីយសាកអាគុយនៅក្នុងប្រទេសកម្ពុជា"
4. អនុស្សារណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការជំរុញការវិនិយោគទ្វេភាគី រវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងភ្នាក់ងារជំរុញការវិនិយោគ និងពាណិជ្ជកម្មកូរ៉េ (KOTRA)
5. អនុស្សារណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជបណ្ឌិត្យសភាកម្ពុជា និងក្រុមប្រឹក្សាស្រាវជ្រាវជាតិសម្រាប់សេដ្ឋកិច្ច មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៃសាធារណរដ្ឋកូរ៉េ
6. កិច្ចព្រមព្រៀងលើឥណទានសម្បទាន សម្រាប់គម្រោងកែលម្អផ្លូវជនបទ ដំណាក់កាលទី៣ និង

7. អនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីរវាង KOTRA និងសមាគមអ្នកសាងសង់កម្ពុជា (CCA) លើកិច្ចសហប្រតិបត្តិការផ្នែកឧបករណ៍និងសម្ភារៈសំណង់។

## តារាងប្រចាំសប្តាហ៍៖ អត្រាកំណើននៃផ.ស.ស របស់ប្រទេសជាសមាជិកអាស៊ាន

តារាងខាងក្រោមនេះ ប្រៀបធៀបកំណើនសេដ្ឋកិច្ច និងកំណើនជាមធ្យមប្រចាំឆ្នាំ នៃប្រទេសសមាជិកអាស៊ាន ពីឆ្នាំ ២០០០-២០១៧។

បន្ទាប់ពីងើបឡើងពីវិបត្តិហិរញ្ញវត្ថុអាស៊ី កំណើនសេដ្ឋកិច្ចរបស់សមាជិកអាស៊ានមានភាពវិជ្ជមាន ដោយអត្រានៃប្រទេសខ្លះមានកម្រិតខ្ពស់ក្នុងចំណោមតំបន់ពាណិជ្ជកម្មពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ កំណើនសេដ្ឋកិច្ច មានភាពខុសគ្នាទៅតាមប្រទេស ដោយប្រទេសមីយ៉ាន់ម៉ាមានអត្រាកំណើនផ.ស.ស.ជាមធ្យមប្រចាំឆ្នាំខ្ពស់ជាងគេគឺប្រមាណ ១០% និងប្រទេសប្រ៊ុយណេមានអត្រាកំណើនទាបជាងគេគឺប្រមាណ ០,៨%។ ប្រទេសកម្ពុជាជាប្រទេសមានកំណើនសេដ្ឋកិច្ចខ្ពស់ទី២ក្នុងតំបន់ ដែលមានកំណើនជាមធ្យមប្រចាំឆ្នាំ ៧,៧%។ ចំណែកឯកំណើនផ.ស.ស. របស់ប្រទេសឡាវមានកម្រិតប្រហាក់ប្រហែលគ្នាដែរគឺ ៧,១%។

| ប្រទេសសមាជិកអាស៊ាន | កំណើនផសស (%) | | | កំណើនជាមធ្យមប្រចាំឆ្នាំ (%) |
|---|---|---|---|---|
| | 2000 | 2010 | 2017 | 2000-2017 |
| ប្រទេសប្រ៊ុយណេ | 2.9 | 2.6 | 1.3 | 0.8 |
| ប្រទេសកម្ពុជា | 8.4 | 6.0 | 6.8 | 7.7 |
| ប្រទេសឥណ្ឌូនេស៊ី | 5.4 | 6.2 | 5.1 | 5.3 |
| ប្រទេសឡាវ | 5.8 | 8.1 | 6.9 | 7.1 |
| ប្រទេសម៉ាឡេស៊ី | 8.9 | 7.4 | 5.9 | 5.1 |
| ប្រទេសមីយ៉ាន់ម៉ា | 13.7 | 9.6 | 6.8 | 10.0 |
| ប្រទេសហ្វីលីពីន | 4.4 | 7.6 | 6.7 | 5.3 |
| ប្រទេសសឹង្ហបុរី | 8.9 | 15.2 | 3.6 | 5.3 |
| ប្រទេសថៃ | 4.5 | 7.5 | 3.9 | 4.0 |
| ប្រទេសវៀតណាម | 6.8 | 6.4 | 6.8 | 6.5 |
| ***អាស៊ាន*** | ***6.0*** | ***7.5*** | ***5.3*** | ***5.3*** |

ប្រភព៖ អគ្គលេខាធិការដ្ឋានអាស៊ាន ទិន្នន័យស្ថិតិអាស៊ាន

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ទីក្រុងបាងកកជាប់ចំណាត់ថ្នាក់ ក្នុងចំណោមទីក្រុងដែលមានតម្លៃថ្លៃបំផុតទាំង១០ នៅតំបន់អាស៊ី

នេះជាលើកដំបូងដែលទីក្រុងបាងកកជាប់ក្នុងចំណោមទីក្រុងដែលមានតម្លៃថ្លៃបំផុតក្នុងអាស៊ីសម្រាប់ជនបរទេស ដែលតម្លៃជួលផ្ទះគិតជាមធ្យមប្រចាំខែស្មើនឹង ៣ ៨៨០ដុល្លារអាមេរិកសម្រាប់ផ្ទះដែលមានបន្ទប់គេងបី។ សម្រាប់ផ្ទះដែលលក្ខណៈដូចគ្នានៅប្រទេសសឹង្ហបុរី បានធ្លាក់ចុះ១,៣% គឺមកត្រឹម ៤ ២១៥ ដុល្លារអាមេរិកក្នុងមួយខែ នេះបើយោងតាមការស្រាវជ្រាវរបស់ស្ថាប័ន ECA International។

យោងតាមស្ថាប័នខាងលើ ការកើនឡើងនៃតម្លៃជួលគឺដោយសារការបន្តការវិនិយោគពីបរទេសនៅក្នុងប្រទេសថៃ ជាពិសេសវិនិយោគពីប្រទេសចិន។ ប្រទេសថៃ នៅតែជាប្រទេសគោលដៅដ៏ពេញនិយមសម្រាប់ សាជីវកម្មពហុសាសន៍ជាច្រើន។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## ធនាគារសហព័ន្ធរក្សាអត្រាថេរ ជាសញ្ញាបង្ហាញថាគ្មានការបង្កើនអត្រាការប្រាក់បន្ថែមក្នុងឆ្នាំនេះ

ធនាគារសហព័ន្ធអាមេរិកបានរក្សាអត្រាគោលរបស់ខ្លួនឱ្យនៅថេរកាលពីថ្ងៃពុធ ដោយបន្តរក្សាអត្រាក្នុងចន្លោះពី ២,២៥%ទៅ ២,៥%។

ធនាគារសហព័ន្ធបានបង្ហាញពីការព្រួយបារម្ភអំពីកំណើនយឺតយ៉ាវនៃសេដ្ឋកិច្ច និងបានផ្តល់ជាសញ្ញាថានឹងមានការកើនឡើងនូវអត្រាការប្រាក់ត្រឹមតែមួយដងប៉ុណ្ណោះ រហូតដល់ឆ្នាំ២០២១ ខណៈពេលដែលការបារម្ភពីអតិផរណាក៏លែងមានផងដែរ (សេចក្តីប្រកាសព័ត៌មាន)។

## ព័ត៌មានសម្រាប់សប្ដាហ៍បន្ទាប់

នៅថ្ងៃសុក្រ ប្រទេសវៀតណាមនឹងចេញផ្សាយទិន្នន័យស្ថិតិទាំងស្រុងរបស់ខ្លួន។ យើងក៏នឹងទទួលបានទិន្នន័យផលិតកម្មឧស្សាហកម្មរបស់ប្រទេសជាច្រើននៅក្នុងតំបន់ផងដែរ ។

ខាងក្រោមគឺជាប្រតិទិនពេញលេញដែលបង្ហាញពីទិន្នន័យ និងការអភិវឌ្ឍនានាដែលក្រុមFACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៥ ខែមីនា ឆ្នាំ២០១៩</u>

- អត្រាអតិផរណារបស់ថៃ សម្រាប់ខែកុម្ភៈ
- ស្ថិតិការលក់រាយរបស់ហ្វីលីពីន សម្រាប់ខែមករា
- អត្រាអតិផរណារបស់សឹង្ហបុរី សម្រាប់ខែកុម្ភៈ
- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់តៃវ៉ាន់ សម្រាប់ខែកុម្ភៈ

<u>ថ្ងៃអង្គារ ទី២៦ ខែមីនា ឆ្នាំ២០១៩</u>

- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់ថៃ សម្រាប់ខែកុម្ភៈ
- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់សឹង្ហបុរី សម្រាប់ខែកុម្ភៈ
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅកូរ៉េខាងត្បូង សម្រាប់ខែមីនា
- ស្ថិតិវិនិយោគដោយផ្ទាល់ពីបរទេសរបស់វៀតណាម សម្រាប់ខែមីនា

<u>ថ្ងៃពុធ ទី២៧ ខែមីនា ឆ្នាំ២០១៩</u>

- ស្ថិតិផលចំណេញឧស្សាហកម្មរបស់ចិន សម្រាប់ខែមករា និងខែកុម្ភៈ
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់ នៅតៃវ៉ាន់ សម្រាប់ខែមីនា
- សន្ទស្សន៍ភាពជឿជាក់ទៅលើពាណិជ្ជកម្ម របស់កូរ៉េខាងត្បូង សម្រាប់ខែមីនា

<u>ថ្ងៃព្រហស្បតិ៍ ទី២៨ ខែមីនា ឆ្នាំ២០១៩</u>

- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅហ្វីលីពីន សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត របស់ម៉ាឡេស៊ី សម្រាប់ខែកុម្ភៈ
- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- ស្ថិតិការលក់រាយរបស់ កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- អត្រានិកម្មភាពរបស់ជប៉ុន សម្រាប់ខែកុម្ភៈ
- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់ជប៉ុន សម្រាប់ខែកុម្ភៈ

<u>ថ្ងៃសុក្រ ទី២៩ ខែមីនា ឆ្នាំ២០១៩</u>

- អត្រានិកម្មភាពរបស់ថៃ សម្រាប់ខែកុម្ភៈ
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត របស់ហ្វីលីពីន សម្រាប់ខែកុម្ភៈ
- ស្ថិតិតុល្យភាពពាណិជ្ជកម្ម របស់វៀតណាម សម្រាប់ខែមីនា
- ស្ថិតិឧស្សាហកម្មផលិតកម្ម របស់វៀតណាម សម្រាប់ខែមីនា
- ស្ថិតិផសស របស់វៀតណាម សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- អត្រាអតិផរណារបស់វៀតណាម សម្រាប់ខែមីនា
- ស្ថិតិការលក់រាយរបស់វៀតណាម សម្រាប់ខែមីនា
- ស្ថិតិតុល្យភាពថវិការបស់ហ្វីលីពីន សម្រាប់ខែកុម្ភៈ
- ស្ថិតិគណនីចរន្តរបស់ថៃ សម្រាប់ខែកុម្ភៈ